ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ១៧៤៧ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១១

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេសរៀបចំឯកសារផ្តល់សច្ចាប័ន លើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ

## រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមការងាររៀបចំឯកសារស្នើសុំការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការនៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១១
- តាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១** .-

ត្រូវបានបង្កើតក្រុមការងារដឹកនាំគ្រប់គ្រង សម្របសម្រួលកិច្ចប្រជុំ ត្រួតពិនិត្យ សរសេរសេចក្តីថ្លែងហេតុ និងចងក្រងឯកសារ ដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអនុម័តលើ ការផ្តល់សច្ចាប័នអនុសញ្ញាអង្គការ សហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| 1. | ឯកឧត្តម | **សែម សុខា** | រដ្ឋលេខាធិការ | ជាប្រធាន |
| 2. | ឯកឧត្តម | **ហង្ស ឡារ៉ាម៉ានី** | រដ្ឋលេខាធិការនៃគណៈកម្មការសិទ្ធិមនុស្សកម្ពុជា | ជាអនុប្រធាន |
| 3. | លោកជំទាវ | **នាង ឆាយយ៉ាណា** | អនុរដ្ឋលេខាធិការ | ជាអនុប្រធាន |
| 4. | លោក | **ឡៅ ម៉េង** | ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ | ជាលេខាធិការ |
| 5. | លោក | **ផ្លុង ឆាយ៉ា** | តំណាងអង្គការ យូនីសេហ្វ | ជាសមាជិក |
| 6. | លោកស្រី | MARINA ORO | តំណាងអង្គការ UNESCO | ជាសមាជិក |
| 7. | លោក | **ឆេត អ៊ិន** | ទីប្រឹក្សាCBR | ជាសមាជិក |

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

| | | | | |
|---|---|---|---|---|
| 7. | លោក | ទី សន | តំណាងអង្គការ CBM | ជាសមាជិក |
| 8. | លោក | អ៊ុខ សម្បត្តិ | អនុប្រធានលេខាធិការដ្ឋានDAC | ជាសមាជិក |
| 9. | លោក | សាត សុផល | អនុប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ | ជាសមាជិក |
| 10. | លោក | ស៊ុម សឿន | ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី | ជាសមាជិក |
| 11. | លោក | មូល ឈន | នាយកមូលនិធិជនពិការ | ជាសមាជិក |
| 12. | លោក | ម៉ា ច័ន្ទណាត | អនុប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ | ជាសមាជិក |
| 13. | លោក | សេត មូហាំម៉ាត់ស៊ីស | អនុប្រធានលេខាធិការដ្ឋានDAC | ជាសមាជិក |
| 14. | លោក | អ៊ុក សុខ | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | ជាសមាជិក |
| 15. | លោក | រស់ ទី | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ | ជាសមាជិក |
| 16. | លោក | ទង់ គុន | មេធាវីនៃឧត្តមស្នងការសិទ្ធិមនុស្សកម្ពុជា | ជាសមាជិក |
| 17. | លោក | ទិន សៅរ័ត្ន | នាយកប្រតិបត្តិអង្គការជនពិការកម្ពុជា | ជាសមាជិក |
| 18. | លោក | ទន សំអាស់ | ប្រធានអង្គការ AeA | ជាសមាជិក |
| 19. | លោក | Mark Morrison | ទីប្រឹក្សាអង្គការHIB | ជាសមាជិក |
| 20. | លោក | នី ញ៉ូ | អនុប្រធាននាយកដ្ឋាន CMAA | ជាសមាជិក |
| 21. | លោកស្រី | ហាស ម៉ៅ | អ្នកសម្របសម្រួលអង្គការARC | ជាសមាជិក |
| 22. | លោក | David curtis | អ្នកសម្របសម្រួលអង្គការARC | ជាសមាជិក |
| 23. | លោក | Jereon Stol | តំណាងអង្គការHIB | ជាសមាជិក |
| 24. | លោក | Benjamin NGUYEN | តំណាងអង្គការHIF | ជាសមាជិក |
| 25. | លោកស្រី | Nancy ROLLINSON | តំណាងអង្គការHIF | ជាសមាជិក |
| 26. | លោកស្រី | ចេន សុភាព | តំណាងអង្គការHIB | ជាសមាជិក |
| 27. | លោក | សែម សុខបញ្ញា | អនុប្រធានផ្នែកគោលនយោបាយច្បាប់DAC | ជាសមាជិក |

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម ៖

- ស្រាវជ្រាវរកឯកសារជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ
- ពិនិត្យឡើងវិញនូវខ្លឹមសារឯកសារអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ
- រៀបចំឯកសារជំនួយស្មារតី
- លើកគម្រោងថវិកាស្នើសុំការជួយពីដៃគូអភិវឌ្ឍនានា
- បកប្រែឯកសារចាំបាច់នានា ទាក់ទងនឹងការងារផ្តល់សច្ចាប័ននេះ
- សរសេរសេចក្តីថ្លែងហេតុ

**ប្រការ២ .-**

ក្រុមការងារត្រូវរៀបចំរបៀបរបបធ្វើការងារជាក់ស្តែងរបស់ខ្លួន ។ រាល់កិច្ចប្រជុំការងារអាចអញ្ជើញតំណាងដៃគូអភិវឌ្ឍ អង្គការជាតិ អន្តរជាតិពាក់ព័ន្ធ និងគ្រប់អង្គភាពជាសមាជិកចូលរួម ។

**ប្រការ៣ .-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន ៖**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ដូចប្រការ ១
- គ្រប់អង្គភាព និងអង្គការដៃគូពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**